# ការសម្ភាសរបស់លោកយាយ រ៉ុស ស៊ី

កៈ អ្នកធ្វើការសំភាសន៏ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៏ឈ្មោះរ៉ុស ស៊ី

កៈ ជាដំបូងសូមជំរាបសួរម៉ា!!

ខៈ ចាស!ជំរាបសួរ!!

កៈ
ចាស!ម៉ាថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងមកសំភាសន៏ម៉ាផ្ទាល់ចឹងកាលសំភាសន៏នេះគឺជាការសំភាសន៏ពីខាងគំរោងរបស់ខាងសាលាBYU Hawai នៅសហរដ្ឋអាមេរិច
ចឹងការសំភាសន៏នឹងត្រូវបានធ្វើឡើងសំរាប់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី៣៥ឡើង
អំពីប្រវត្តិរូបរបស់គាត់នឹងអំពីបទពិសោធន៏ដែលគាត់បានឆ្លងកាត់
ជីវិតរបស់គាត់ដែលគាត់បានឆ្លងកាត់តាំងពីសម័យមុនមកដល់ឥឡូវនឹង
ចាសហើយចឹងយើងចង់ចង់ក្រងសារដើម្បីនឹងទុកសំលេងរបស់គាត់នឹងអោយក្មេងៗជំនាន់ក្រោយអោយគេបានដឹងថានេះគឺជាកាលពីមុនអីគឺកាលពីមុននឹងចាស់ៗកាលពីមុនមកនឹងគាត់មានការលំបានច្រើនហើយគាត់មានជីវិតតស៊ូរហូតមកដល់ឥឡូវនេះ
ហើយសំរាប់កូនចៅរបស់ម៉ាផ្ទាល់ដែលគាត់ចេះប្រើអ៊ីនធឺណែតដែលគាត់ចេះប្រើហើយគេអាចចូលទៅក្នុងវេបសាយរបស់ខាងសាលានឹងគាត់អាចនឹងស្តាប់សំលេងរបស់ម៉ា
យកសំលេងមួយនឹងស្តាប់ថាម៉ាមានប្រវត្តិខ្សែស្រឡាយរហូតមក
ដែលយើងនឹងធ្វើការចង់ក្រងសារមួយនឹងទុកអោយពួកគាត់ដែលជាក្មេងជំនាន់ក្រោយនឹងគេបានដឹងនឹងបានស្គាល់បានលឺកុំអោយបាត់បង់ចឹងណាម៉ា។

ខៈ ចាសៗ!

កៈ ចឹងតើម៉ាអាចមានពេលដើម្បីអោយខ្ញុំនឹងធ្វើការសំភាសន៏ម៉ាដែលឬទេ?

ខៈ ចាស!ខ្ញុំអនុញ្ញាតអោយ។

កៈ ចាស!ចឹងជាដំបូងតើម៉ាមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំមានឈ្មោះថា រ៉ុស ស៊ី។

ក៖ តើឈ្មោះរបស់ម៉ានឹងត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណដែលឬទេ?

ខ៖ ចាស!ត្រូវ។

ក៖ ចឹងតើឈ្មោះម៉ានៅក្នុងអត្តសញ្ញាបណ្ណ័នឹងមានឈ្មោះអ្វីដែលទៅម៉ា?

ខ៖ នឹងឈ្មោះនឹងតែម្តងនឹង។

ក៖ ចាស! ហើយម៉ាមានឈ្មោះប៉ុន្មានឆ្នាំហើយឆ្នាំនឹង?

ខ៖ ខ្ញុំមានអាយុជិត៩០អីអាយុអឺ អាយុ៧០ហើយ។

ក៖ ចាស!ចឹងឆ្នាំនេះម៉ាមានអាយុ៧០ឆ្នាំហើយ?

ខ៖ ចាសៗ!!!

ក៖ ហើយម៉ាមានបានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែលឬទេ?

ខ៖ អូ!ដូចជាអត់បានចាំទេកូនអើយដូចជាបានភ្លេចហើយខ្ញុំ។ភ្លេចហើយ

គ៖ គ្រាន់តែបានចាំឆ្នាំរបស់ខ្លួន។

ខ៖ បានតែចាំឈ្មោះរបស់ខ្លួនឯងនឹងណា
ភ្លេចហើយខ្ញុំមិនបានចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនឯនោះទេភ្លេចហើយខ្ញុំ។

ក៖ ចាស!!!

គ៖ ខ្ញុំនឹងក៏បានភ្លេចច្រើនណាស់ដែល។

ក៖ ចាស!ម៉ាចឹងម៉ាមានឪពុកម្តាយឈ្មោះអ្វីដែលទៅម៉ា?

ខ៖ ឪពុកម្តាយរបស់ខ្ញុំហ៎?

ក៖ ចាស!!!

ខ៖ ឈ្មោះរបស់ពួកគាត់នឹងមានឈ្មោះថា យាយនាង តាហល ចាស។

ក៖ ចាស!ហើយចឹងគាត់មានកូនប៉ុន្មាននាក់ដែរដែលត្រូវជាបងនឹងប្អូនរបស់យាយ?

ខ៖ មានតែខ្ញុំ១នាក់ឯងគត់។

គ៖ មានតែម្នាក់ឯងនឹង។

ខ៖ ចាស!ម្ដាយរបស់ខ្ញុំនឹងគាត់មានកូនតែខ្ញុំ១នោះទេ។

ក៖ ចឹងម៉ាគឺជាកូនទោលណំ?

ខ៖ ចាស!!!

ក៖ ហើយគាត់មានទីលំនៅនៅកន្លែងណាដែរ?

ខ៖ ទីលំនៅនឹងគឺគាត់នៅកន្លែងនឹងតែម្ដងនឹងថៅ។

ក៖ អឺតើម៉ាអាចបញ្ជាក់ភូមិ ឃុំនឹងខេត្តបានដែរឬទេ?

ខ៖ ភូមិនឹងមានឈ្មោះថា ភូមិខ្ពប ហើយឃុំ ខ្ពប នឹងស្រុកកោះឧញ្ញាតី នឹងចាស។

ក៖ ចាស! ចាស!ហើយសព្វថ្ងៃនឹងម៉ាមានទីលំនៅនៅទីនេះតែម្ដងផ្ទាល់តែម្ដង?

ខ៖ ចាស!សព្វថ្ងៃនឹងខ្ញុំមានទីលំនៅនៅនឹងតែម្ដង ទីលំនៅរបស់ខ្ញុំនឹងគឺនៅនឹងម៉ង់។

ក៖ ចាស!ចឹងទីលំនៅកំណើតរបស់លោកយាយក៏នៅនឹងដែរ?

ខ៖ ចាស! ទីលំនៅកំណើតក៏នៅទីនេះដែរ។

ក៖ ចាស!ម៉ា
ហើយចុះម៉ាពេលដែលម៉ាកាលនៅពីក្មេងៗនឹងតើម៉ាមានបានរៀនដល់កំរិតណាដែរម៉ា?

ខ៖ អូ!
កាលដែលខ្ញុំនៅពីក្មេងនឹងខ្ញុំបានរៀនមកពីសង្គមមកនឹងបានត្រឹមតែថ្នាក់ទី២អីចឹងនឹងទេកូន
មិនបានរៀនជ្រៅជ្រះនឹងគេនោះទេព្រោះអីកាលនឹងម្ដាយឪពុកយើងនឹងជាអ្នកអត់មាននឹង

ណាចឹងហើយដល់ពេលដែលម្ដាយឪនឹងគាត់ជាអត់សូវមានចឹងខ្ញុំនឹងក៏មិនបានរៀនច្រើនដែរ ឡែនតែទៅមើលគោមើលអីចឹងទៅណាហើយក៏ចឹងទៅហើយណាមួយទៀតនឹងដោយសារតែ ខ្ញុំនឹងបានកំព្រាឪពុកតាំងពីអាយុបាន១៣ឆ្នាំមកម្លេះ
ចាសហើយខ្ញុំនឹងបានមើលតែគោនឹងទៅខ្ញុំនឹងមិនបានមើលរៀនអីបានជ្រៅជ្រះនោះទេកាល នោះនឹង។

ក៖ ចាស!ហើយចឹងកាលនឹងម៉ាបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរម៉ាឈប់រៀនម៉ានៅចាំដែរឬទេ?

ខ៖ កាលនៅពីសង្គមនឹងបានត្រឹមថ្នាក់ទី២កូន ដូចជាស្រះអ នឹងស្រះអា
ពេលដែលបានឡើងទៅថ្នាក់ទី២ចឹងទៅណាកូន
ចាសកាលនឹងយើងរៀនបានតែប៉ុណ្ណឹងនោះទេខ្ញុំរៀនមិនបានសូវជ្រៅជ្រះនឹងគេនោះទេខ្ញុំ នោះ។

ខ៖ ហើយសាលានឹងនៅឯណាដែលម៉ា?

ក៖ សាលានឹងនៅឯកោះយើងនឹងដែលនៅឯវត្តនឹង

គ៖ ខ្ញុំលាទៅសិនហើយ

ខ៖ ចាសៗ!!

ក៖ ចាស!ម៉ា

ក៖
ចាស!ម៉ាហើយពេលដែលម៉ាបានសិក្សាហើយនឹងដល់ពេលដែលម៉ាបានសំរេចចិត្តនឹងឈប់ ការសិក្សានឹងដោយសារតែម៉ាបានបញ្ចប់ថ្នាក់ឬក៏ម៉ាដោយសារតែជីវៈភាព?

ខ៖ ដោយសារតែជីវៈភាពចាស
ពេលដែលខ្ញុំបានបញ្ចប់ថ្នាក់នឹងដោយសារតែជីវៈភាពរបស់ខ្ញុំវាមើលទៅដូចជាខ្សត់ខ្សោយពេ កមើលទៅនឹងដូចជាម្ដាយរបស់ខ្ញុំនឹងគាត់មិនអាចនឹងរកចិញ្ចឹមកូនណា
នែកបានទេចឹងហើយមិនបានរៀនសូត្រអីច្រើននោះទេព្រោះអីពេលនឹងគាត់ក៏ជាស្ត្រីមេម៉ាយ ដែល

ដល់ចឹងទៅជីវៈតែ២នាក់ម្ដាយនឹងកូននឹងខ្ញុំនឹងក៏ទៅមើលគោទៅម្ដាយនឹងគាត់បានទៅលក់ដូរអីបន្តិចបន្តួចអីចឹងទៅ
ទៅប៉េះអីសំរាប់យកមកលក់ចឹងទៅដូចជាមានស្លឹកបាសស្លឹកអីទៀតនឹងយកទៅលក់នៅឯភ្នំពេញទៅចឹងទៅបានអីមកបន្តិចបន្តួចចឹងមកខ្ញុំនឹងគឺកំសត់ណាស់
កាលពីក្មេងមករហូតមកដល់សម័យនេះនឹងវាកំសត់ណាស់កូនអើយទើបតែបានមកដល់ជំនាន់នេះទេដែលបានកូនខ្ញុំនឹងបាន២នាក់កូនប្រុស១នឹងស្រី១នាក់ទៀតនឹងសព្វថ្ងៃនឹងចាសបានរាងធូរធានដោយសារមានកូននឹងចឹងទៅ ខ្ញុំវារាងគ្រាន់បើដែលណា

ក៖ ចាស!

ខ៖ វាមិនសូវជាវេទនាដូចជាកាលនៅពីក្មេងនោះនឹងពេកនោះទេ។

ក៖ ចាស! ម៉ាមានបងនឹងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំអត់មានទេគឺមានម្នាក់ឯងនឹងគត់តែម្ដង។

ក៖ ចាស!ហើយចុះបងប្អូនជីដូនមួយជីក៏អត់មានដែរម៉ា?

ខ៖ បងប្អូនជីដូនមួយនឹងមាន ប៉ុន្តែគេនៅឆ្ងាយៗ

ក៖ អូ! ពួកគាត់នៅឆ្ងាយៗពីនេះណ៎ម៉ា?

ខ៖ ចាស!គេនៅឆ្ងាយៗពីនេះគេនៅឆ្ងាយពីខ្ញុំ។

ក៖ ប៉ុន្តែសព្វថ្ងៃតើម៉ានឹងពួកគាត់នៅតែមានទំនាក់ទំនងគ្នាដូចជាមកលេងគ្នាមកលេងមកអីដែរឬទេ?

ខ៖ ចាស!មានទំនាក់ទំនងគ្នាដូចជាមុននឹងមិញនឹងមីក្មួយហើយនឹងដែលវាបានមកដើរប្រាប់បុណ្យមុននឹង ចាស។

ក៖ ចាស! ហើយម៉ាមានកូនប៉ុន្មានដែរនៅក្នុងបន្ទុក?

ខ៖ នៅក្នុងបន្ទុកមានតែ២នាក់នឹង។នៅក្នុងបន្ទុកហ៎?
នៅក្នុងបន្ទុកខ្ញុំសព្វថ្ងៃនឹងមានតែកូននឹងមានតែកូនតែមួយនោះទេ

បើអាប្រុសរបស់ខ្ញុំនឹងវានៅធ្វើការនៅឯស្រុកពោធិសាត់ឯនោះ ហើយចំណែកឯកូនរបស់ខ្ញុំនឹងមួយនឹងមីបងគេបង្អស់នឹងនៅជាមួយនឹងម្តាយមីងរបស់ខ្ញុំនឹងគេបង្អស់នឹងចាស។

ក៖ ពួកគាត់មានឈ្មោះអ្វីខ្លះទៅ?

ខ៖ កូនរបស់ខ្ញុំនឹងមីបងនឹងមានឈ្មោះថា សុវណ្ណា កូនប្រុសដែលបានទៅធ្វើការនៅឯពោធិសាត់នឹងឈ្មោះរបស់គេនឹងឈ្មោះថាសុន សុផលនឹង។

ក៖ ចាស!ហើយពួកគាត់បានរៀបអាពាហ៏ពិពាហ៏ទាំងអស់គ្នាហើយម៉ា?

ខ៖ ចាស! អូ!ប៉ុន្មានកូនរបស់ខ្ញុំអាប្រុសនឹងអត់ព្រមយកគ្រួសារតែគឺគេនៅលីវ នៅលីវរហូតមិនព្រមទេកូនអើយ មិនព្រមអត់ព្រមយកគ្រួសារនោះទេ។

ក៖ ហឺ!!ហើយចំណែកឯម៉ាវិញដូចជាពេលដែលម៉ាបានយកគ្នាជាមួយនឹងលោកពូនឹងត្រូវជាស្វាមីរបស់ម៉ានឹងតើគាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះថាសុនចឹង

ក៖ គាត់មានមុខរបរជាអ្វីដែលម៉ា?

ខ៖ គាត់ជាអ្នកធ្វើចំការអីទេកូនអើយ អត់មានធ្វើអ្វីនោះទេ គាត់ជាអ្នកដែលធ្វើចំការចំអីនឹងមានមុខរបរជាអ្វីនោះទេ។

ក៖ ចុះចំណែកឯម៉ាវិញតើសព្វថ្ងៃនឹងតើម៉ាមានមុខរបរជាអ្វីដែរ?

ខ៖ សព្វថ្ងៃនឹងខ្ញុំមានមុខរបរនឹងគ្រាន់តែជាអ្នកដែលខាលស្វត្រអោយកូនចាក់តែប៉ុណ្ណឹងទេអត់មានអីនោះទេ ហាហ រាល់ថ្ងៃនឹងគ្មានបានទៅណានោះទេហើយក៏ឈឺគ្មានបានទៅណានោះទេខ្ញុំនឹង។

កៈ ហើយការធ្វើស្វូត្រនឹងក្នុង១ថ្ងៃតើយើងអាចរកបានចំណូលបានប៉ុន្មានដែរម៉ា?

ខៈ
ហឺ!ពិបាកណាស់កូនអើយយើងជាអ្នកខាលចឹងប៉ុន្តែបើយើងទៅស៊ីឈ្នួលអោយគេវិញយើងបាន១គីឡូងបាន៣០០០០រអីចឹងដែលនឹងណាប៉ុន្តែខ្ញុំនឹងវាធ្វើមិនដល់នោះទេគ្រាន់តែបានជួយកូនបានតែ២ទៅ៣អំពុងនោះទេព្រោះអីខ្ញុំនឹងវាមានកំលាំងខ្សោយវាចេះតែឈឺនោះ កៈ ចាស!!!

ខៈ
និយាយថាបើថាធ្វើការងារធ្ងន់នឹងហើយអង្គុយយូរទៅមិនបាននោះទេព្រោះអីវាចេះតែខ្សោយឡើងដើបឡើងនឹងវិលមុខតែម្តងចឹងហើយខ្ញុំនឹងមិនសូវជាពូកែធ្វើបានច្រើននោះទេព្រោះអីនឹងខ្ញុំវាពូកែឈឺ។

កៈ
ចាស!ហើយចឹងម៉ាគិតថាការងារមួយនឹងម៉ាអាចនឹងធ្វើវាបានប៉ុន្មានដែរដែលអាចអោយម៉ាចិញ្ចឹមជីវិតនឹងក្រុមគ្រួសាររបស់ម៉ាបាន?

ខៈ
ខ្ញុំអើយខ្ញុំវាធ្វើនឹងរយៈពេលនឹងវាឡើងយូរដែលហើយដែលខ្ញុំបានធ្វើអោយកូននឹងវាឡើងយូរដែលហើយដែលខ្ញុំចេះតែធ្វើហើយត្បាញ់យកទៅអោយគេទៅហើយមានខាលអោយគេចឹងទៅ។

កៈ ចាស!!
ហើយការងារនឹងម៉ាបានរៀនចេះពីក្រុមគ្រួសារខ្លួនឯងតៗគ្នាឬក៏ម៉ាចេះពីការទៅមើលគេតៗគ្នាអីចឹងណា?

ខៈ ខ្ញុំចេះពីខ្លួនរបស់ខ្លួនខ្ញុំផ្ទាល់នឹងបានទៅមើលគេនឹងចេះពីក្រុមគ្រួសារអីដែលយើងធ្វើការពីដើមៗមកនឹងបទពីសោធន៍ដែលយើងមានឹងដែលកាលពីដើមមកនឹងខ្ញុំបានធ្វើជាអ្នកត្បាញ់ក្រមាចឹងទៅណាហើយដល់ពេលដែលយើងបានធ្វើក្រមាចឹងទៅយើងធ្លាប់ខាលនឹងធ្វើបានធ្វើចឹងហើយធ្លាប់ត្បាញអីចឹងទៅមកដល់ដំណាក់កាលដែលយើងត្រូវត្បាញសូត្រអីចឹងទៅយើងនឹងក៏ចេះត្បាញ់ដែលចឹងទៅ។

ក៖
ហើយពេលដែលបានធ្វើហើយនឹងតើម៉ាបានយកទៅលក់អោយឈ្មួញគេដែលគេមកទិញពីម៉ានៅកន្លែងឬក៏ម៉ាធ្វើការយកទៅអោយគេនៅដល់កន្លែងតែម្តង?

ខ៖ ខ្ញុំនឹងគឺកូននឹងវាយកទៅលក់អោយថៅកែវាតែម្តងនឹងចឹងណាកូនអាសំភារៈអីនឹងវាលើគេពេលដែលយើងធ្វើហើយយើងត្បាញបានសំពត់នឹងហើយយើងត្រូវយកទៅអោយម្ចាស់គេចឹងណាយើងត្រូវយកទៅអោយម្ចាស់គេចឹងទៅណាកូនយើងទៅយកអោយគេចឹងទៅ
ដូចថាក្នុង១ក្បិនគេ១ក្បិនយើងដូចថាពេលដែលយើងបានត្បាញ់ហើយនឹងយើងបានយក១ក្បិនទៅអោយគេហើយ១ក្បិនទៀននឹងយើងយកពីគេមកវិញ
ហើយពេលដែលយើងបានលុយមកសំរាប់ទុកគ្រាន់អោយក្រុមគ្រួសារយើងហូបចុកអីចឹងទៅណា។

ក៖ ចាស!អូ!ម៉ាពូកែមែនទែនដែលបានធ្វើ
ហើយអីមានការធ្វើតាំងពីក្រមានឹងតាំងពីសូត្រដែលម៉ាអាចធ្វើបាន
ហើយក្នុង១ថ្ងៃតើម៉ាអាចធ្វើបានជាមធ្យមនឹងតើម៉ាអាចធ្វើបានប៉ុន្មានក្បិនដែរ?

ខ៖ អានឹងសំរាប់ខ្ញុំអត់បានត្បាញ់ហើយនិយាយតែអាខ្ញុំបានតែខាលអោយទៅកូននឹងទេណា

ក៖ ចាស!ចឹងនិយាយតែរឿងម៉ាបានខាលអោយទៅកូនទៅម៉ា

ខ៖
និយាយទៅឥឡូវនឹងមានថៅនឹងគេបានចេះត្បាញ់គេត្បាញបាន១អាទិត្យនឹងគេត្បាញ់បានក្នុង១អាទិត្របាន១ក្បិន។

ក៖ អានឹង១អាទិត្យបាន បាន១ក្បិន?

ខ៖ ចាស១អាទិត្យបាន១ក្បិនចាស

ក៖ យើងលក់ចេញនឹងបានតំលៃប៉ុន្មានដែលទៅម៉ា?

ខ៖ អត់បានច្រើននោះទេយើងលក់ចេញនឹងបាន១០០៛ជាងបាន១១០៛ចាស។

ក៖ ចាស!ហើយគេបានមកយើងដល់កន្លែងតែម្តង?

ខ៖
ចាស!ប៉ុន្មានដូចថានៅក្នុងសំពត១ក្បិនចឹងពេលដែលយើងធ្វើហើយនឹងយើងត្រូវកាត់ណាកូន
យើងត្រូវកាត់យកទៅអោយថៅកែគេចឹងទៅចាស។

ក៖ ចាស!
ចឹងម៉ាមានបងនឹងប្អូនប៉ុន្មាននាក់ដែរអូប៉ុន្តែម៉ាបានប្រាប់ថាម៉ាមានបងនឹងប្អូនតែម្នាក់ទេម៉ានេ
ស
ហើយម៉ាបងប្អូនម៉ាដូចជាបងប្អូនជីដូនមួយអីរបស់ម៉ាតើគាត់មានបានធ្លាប់ស្លាប់នៅក្នុងជំនាន់
អាពតដែរឬទេម៉ា?

ខ៖ ហឺគេនឹងធ្លាប់មានកូន
ធ្លាប់មានបងប្អូនជីដូនមួយអីនឹងដែលគេនៅឆ្ងាយៗពីយើងដូចថាគេនៅរហូតដល់វត្តកោះអីចឹ
ងទៅណាហើយយើងនឹងនៅឯនេះទេតែគេនឹងបាននៅរហូតដល់វត្តកោះអីចឹងទៅណាដែល
គេនៅឆ្ងាយពីយើងហើយកាលនគេបានស្លាប់នៅគេស្លាប់នៅក្នុងជំនាន់អាពតនឹង។

ក៖ កាលនឹងម៉ាមានបាននៅទាន់ពួកគាត់ទេពេលដែលពួកគាត់ស្លាប់នឹង?

ខ៖ ពេលនឹងគេបានជំលៀសគាត់ទៅហើយខ្ញុំនឹងនៅតែកន្លែងនឹងទេ
ពេលជំនាន់នឹងណាកូនហើយពេលនឹងខ្ញុំនឹងនៅតែផ្ទះទេខ្ញុំនៅបានតែកន្លែងនឹងគេមិនបានជំ
លៀសខ្ញុំនោះទេកាលនឹងនោះ កាលនឹងគេអោយខ្ញុំនឹងនៅក្នុងភូមិនឹងតែម្តង
ប៉ុន្តែគ្រាន់តែខ្ញុំនឹងកាលនៅជំនាន់អាពតនឹងគេអោយខ្ញុំនឹងទៅធ្វើស្រូវនៅឯស្រែខាងកើតឯ
ណោះ
ចាសនៅឯស្រែនៅខាងកើតឯណោះហើយដំពេលចឹងទៅខ្ញុំបានទៅបែកគ្នាជាមួយនឹងគ្រួសារ
ហើយពេលនឹងទឹកវាបានឡើងមកនឹងវាបានលេចអស់ស្រែអីនឹងបានខ្ញុំគេអោយមកផ្ទះកាល
ជំនាន់នឹងនោះកាលនឹងខ្ញុំវាវេទនាណាស់ខ្ញុំ។

ក៖ ហឺ! គេជំលៀសម៉ាទៅណាដែល?

ខ៖
អត់មានបានជំលៀសទេកូនកាលនឹងគេគ្រាន់តែធ្វើការបញ្ជូនយើងនឹងទៅអឺគេអោយយើងនឹង
ទៅធ្វើស្រុវណាកូនចាស

ហើយបើគ្រួសាររបស់ខ្ញុំនឹងគេបានជំលៀសដូចជាឪពុកម្ដាយនឹងប្អូនរបស់ម្ដាយខ្ញុំណាគេបានយកពួកគាត់ទៅជំលៀស ទៅដល់ឯបាត់ដំបង់ចាស
បាត់ដំបងដូចជាឪពុកក្មេកខ្ញុំអីគាតបានស្លាប់នៅនោះទាំងអស់។

ក៖ ហើយកាលនឹងគេបានប្រើម៉ាអោយធ្វើអ្វីខ្លះទៅកាលនឹង?

ខ៖ កាលនឹងនៅជំនាន់អាពតនឹងគេបានប្រើខ្ញុំនឹងអោយទៅកាត់ពោត
ស្ទូងស្រូវអីនឹងណានៅឯស្រែខាងកើតនឹងដែលគេបានហៅថាស្រែនៅប៉ាននោលនឹងវានៅឆ្ងាយណាស់កូនអើយ
ហើយពេលនឹងណាខ្ញុំនឹងបានក្រោកឡើងទៅណាហើយកាលនឹងពេលដែលបានក្រោកឡើងនឹងគេបានវៃជួងដើម្បីអោយយើងនឹងក្រោកឡើងដើម្បីទៅនឹងណាហើយពេលដែលយើងទៅនឹងជូនកាលនឹងវាមានភ្លៀងអីចឹងទៅហើយបានដើរទៅតាមផ្លូវស្រែនឹងវាឡើងរអិលមានពេលខ្លះទៅនឹងខ្ញុំយំតាមវាលស្រែនឹងក៏មានដែលវាវេទនាណាស់កាលនៅជំនាន់នោះ
មហាវេទនាហើយកាលនៅជំនាន់នោះវាវេទនាមែនទែន។

ក៖ ហើយកាលនឹងគេមានបានធ្វើបាបម៉ាដែលឬទេកាលនឹង?

ខ៖
ជំនាន់អត់ទេកាលនឹងខ្ញុំដូចជាពេលដែលខ្ញុំបានទៅធ្វើការងារនៅឯនោះនឹងក៏គេមិនដែលមកធ្វើបាបអីយើងដែលប៉ុន្តែពេលនឹងគេគ្រាន់តែអោយយើងនឹង
ដូចជាពេលដែលគេអោយយើងក្រោកឡើងពេលដែលគេវៃជួងនឹងគេអោយយើងនឹងទៅស្ទូងព្រោះអីកាលនឹងវានៅឆ្ងាយនោះអីស្រែនឹងនោះចាស
ហើយបើនិយាយពីចំងាយពីការដ្ឋាននឹងទៅស្រែដែលយើងទៅស្ទូងនឹងវានៅឆ្ងាយណាស់ចាស ហើយពេលដែលគេវៃជួងនៅម៉ោង១នឹងគេអោយយើងត្រូវចេញទៅស្ទូងហើយ
ទៅស្ទូងស្រូវទៅកូនអានឹងវាចឹងឯង
អានឹងនិយាយតែប៉ុណ្ណឹងទេណានៅចំណែកឯអារឿងបបរទៀត
គេយកពោតក្រហមនឹងមកបបរគេបបរអោយយើងហូបនឹងគេបបរពោតក្រហមអោយយើងហូបដូចជាសត្វជ្រូកចឹង។

ក៖ កាលនឹងគេអោយបបរនឹងប៉ុន្មានពេលដែលរបបអាហារនឹង?

ខ៖
គេអោយបើនិយាយទៅគេបានអោយ២ពេលដែលនឹងគេបានអោយយើងនឹងបាន២ពេលដូចជានៅពេលថ្ងៃនឹងនៅពេលល្ងាចអីចឹងទៅណាកូន គេ បានអោយយើងនឹងតែ ២ពេលនឹងទេ។

ក៖
ចាស!ហើយពេលនឹងគេបានអោយម៉ានៅមុខម្ហូបអីគេខ្លះដែរម៉ាមានបានចាំដែរឬទេសំរាប់អោយម៉ាពិសារ?

ខ៖
កាលនៅជំនាន់នោះវាវេទនាណាស់កូនអើយកាលនឹងគេគ្មានបានអោយយើងនឹងនូវអាហារសំរាប់ហូបអីទេ បើថាឡអីដូចជាស្លឹងសន្ដាន់អីគេទេកាលនឹងនោះ
ត្រីដូចជាត្រីរៀលយើងនឹងប៉ុនៗមេដៃដែលគេខ
កាលនឹងដែលគេខសំរាប់អោយយើងនឹងម្នាក់បានតែ១នឹងទេកាលនឹងជំនាន់នោះម្នាក់បានតែមួយនឹងតេកាលជំនាន់នោះវាវេទនាណាស់។

ក៖
ចាស!ចឹងជីវិតរបស់ម៉ាគឺមានការតស៊ូមែនទែនហើយពេលដែលបានដាច់អាពតមកនឹងជីវិតរបស់ម៉ារឹតតែមានការតស៊ូទៀតហើយចឹង?

ខ៖ ចាស!តស៊ូណាស់
ខ្ញុំបានតស៊ូសំរាប់កូនមកទល់សព្វថ្ងៃមកធ្វើចំការទំរាំតែប្ដីរបស់ខ្ញុំនឹងគាត់បានខូតទៅនឹងខ្ញុំក៏លែងបានធ្វើអ្វីកើតព្រោះអីកាលនឹងខ្ញុំនឹងក៏ឈឺដែលចឹងចាស
ឈឺមករហូតនឹងរហូតមកទល់សព្វថ្ងៃនឹងមិនបានធ្វើអ្វីកើតនោះទេបានតែខាលស្លូត្រនឹងសំរាប់ទុកអោយចៅនឹងសំរាប់អោយគេយកទៅត្បាញនឹងសព្វថ្ងៃនឹងនោះ។

ក៖
ចុះជីវិតរបស់ម៉ាពេលដែលបានការជាមួយនឹងលោកពូតើនៅពេលដែលការនឹងក្នុងជំនាន់អាពតឬក៏បានដាច់អាពតហើយ?

ខ៖ ខ្ញុំហ៎

ក៖ចាស!!

ខ៖ ការនឹងតាំងពីមុខអាពតទៀតតាំងពីសម័យមុខ។

ក៖ អូ!ចឹងតាំងពីមុខអាពតមកទៀត?

ខ៖ ចាស!តាំងពីសម័យជំនាន់របស់សម្តេចមកម៉េច។

ក៖
ចាស!ចឹងកាលនឹងម៉ានឹងលោកពូស្រលាញ់គ្នាដោយចិត្តនឹងចិត្តឬក៏ឪពុកម្តាយគាត់ជាអ្នកដែលបានរៀបចំអោយ?

ខ៖ ចាស!កាលនឹងឪពុកម្តាយគាត់ជាអ្នកដែលជួយរៀបចំអោយទេកូន
តែពេលនឹងគាត់បានចូលមកដណ្តឹងត្រឹមត្រូវតែណា
អត់មានថាស្រោត់តែនឹងចិត្តរបស់ខ្លួនឯងនោះទេកាលនោះជំនាន់នោះនឹងចាស់ៗនឹងគាត់ជាអ្នកគិតគូរនឹងផ្សំផ្គុំអោយនឹងគាត់ទាល់តែសួរចិត្តរបស់កូនដែលនឹងកាលជំនាន់នោះណាកូនជំនាន់នឹងវាមិនដូចជាឥឡូវនោះទេ ហាហា

ក៖ ចាស!!!
ហើយលោកពូកាលនឹងគាត់បានធ្វើមុខរបរអ្វីគេដែរកាលនឹងកាលនឹងជំនាន់សម័យសង្គមនឹង?

ខ៖ កាលនៅជំនាន់សង្គមនឹងដែលគាត់ថាចង់បានខ្ញុំនឹងគឺគាត់ជាអ្នកដាក់ឈើកាលនឹងនោះគាត់ជាអ្នកដាក់ឈើកាលនឹងនោះដូចថាកាលនឹងគាត់នឹងជាអ្នកដែលដាក់ឈើចង់ក្បូននឹងណាហើយចឹងវាមានតែចឹងនឹងណាការងារនឹងនោះ។

ក៖
ហើយចុះចំណែកឯជំនាន់នឹងម៉ាមានមុខរបរជាអ្វីដែលកាលនឹងនោះកាលនៅជំនាន់សង្គមនឹងនោះ?

ខ៖ កាលនឹងខ្ញុំជាអ្នកត្បាញក្រមា។

ក៖ ចឹង

ខ៖ ចាស!!!

ក៖ ហើយកាលនឹងតាំងពីសង្គមនឹងរហូតមកដល់ឥឡូវនឹង?

ខ៖ ចាស!!!

ក៖ ហើយចឹងម៉ាមិនបានភ្លេចឡើយពីវិធីត្បាញក្រមានឹង?

ខ៖ ចាស!អត់បានភ្លេចនោះទេ ។

ក៖
ចាស!ហើយអើយកាលនៅសម័យជំនាន់សង្គមនឹងតើម៉ាមានទិដ្ឋភាពអីដែលឬទេដែលអាចធ្វើអោយម៉ាចង់ចាំមករហូតមកដល់ឥឡូវដែលម៉ាបានចង់ចាំតាំងពីសម័យមុខនឹងដែលឬទេម៉ា?

ខ៖ កាលនៅសម័យពីសង្គមមកហ៎?

ក៖ ចាស!!!

ខ៖
ហឺ!ដូចជាគ្មានរឿងអីទេកាលនៅពីមុនមកនឹងដូចថាពេលពីមុនមកនឹងដូចថាពេលនឹងដូចជាមិនបានអីនោះទេប៉ុន្តែកាលនឹងដូចថាវារាងស្រួលរកស៊ីហើយដូចថាវាស្រួលដូចជាការធ្វើការងារអីនឹងហើយវាស្រួលក្នុងការលក់ដូរអីចឹងដែរដូចថាវាមិនលំបាកដូចជាពេលឥឡូវនឹងដែលមើលទៅនឹងវារាងវេទនានោះពេកណាកូន ចាស

ក៖ ចាស!!!

ខ៖
ចាស!ដូចថាពេលនឹងយើងបានលក់ដូរអីចឹងទៅមិនអោយយើងនឹងនៅវេទនាចឹងដែលចឹងវាបានលក់ដូរអីចឹងដែល។

ក៖ ចាស!ដូចថាពេលនឹងម៉ាអាចលក់បានថ្លៃ?

ខ៖
ចាស!កាលនឹងវាថាដូចជាបានលក់បានថ្លៃជាងនៅជំនាន់នេះនឹងណាវាមិនដូចនៅក្នុងជំនាន់

នេះទេណាដូចជាពេលនឹងវាលក់បានថ្លៃប៉ុន្តែវាមិនបានគ្រាប់គ្រាន់នោះទេព្រោះអីពេលដែលលក់ទៅនឹងវារាងបានច្រើនដែលតែវាចាយមិនបានគ្រាប់គ្រាន់នឹងណាចឹងហើយបានថាវានិងមិនបានល្អចឹងសុខចិត្តដូចកាលពីមុនវាលក់បានថោកតែមានតំលៃចាយបានច្រើនហើយនៅសល់
ដែលគេថាលុយវាថ្លៃតែរបស់នឹងវាថោកចឹងណាទៅដូចថាវាគ្មានអីនោះទេដូចថាវាបានថ្លៃចាយវាច្រើនចឹងទៅ ហាហាហា

កៈ ចាស!
ហើយកាលពីសម័យបន្ទាប់មកទៀតដែលម៉ាបានឆ្លងកាត់មកពីសម័យពពតនឹងមកតើម៉ាបានចង់ចាំអ្វីជាងគេនៅពេលនឹងនៅក្នុងជីវិតរបស់ម៉ាណា?

ខៈ
កាលនឹងខ្ញុំគ្មានបានចាំអីក្រៅពីកាលស្ទូងការដកនឹងទេកាលនឹងនោះគឺវាចាំអាកន្លែងនឹងតែម្តងគឺចាំជាងគេនឹងគឺនៅពេលដែលគេបានប្រើយើងនឹងអោយទៅស្ទូងដកនឹងតែម្តងនឹងវាលំបាកពេក
ហើយពេលនឹងកូនទុកនៅចោលនៅឯផ្ទះចឹងហើយយើងត្រូវទៅស្ទូងនៅឯស្រែចឹងទៅនៅឆ្ងាយណាកូនអើយ នៅដល់ប៉ានណោលឯនោះ
នៅឯស្រែខាងកើតឯនោះចឹងបានថាវាពេលនឹងបានចោលកូនអីចឹងទៅកាលនឹងដើម្បីនឹងទៅធ្វើស្រែចឹងទៅ
កាលនឹងបានទៅចោលកូននឹងចឹងទៅដែលកាលនឹងក្នុងសម័យអាពតនឹងវាវេទនានឹងត្រង់ថាវាមិនអោយយើងនឹងស៊ីបានឆ្អែកនោះទេហើយមួយទៀតនឹងវានឹងអោយយើងនឹងទៅស្ទូងស្រូវ វាបបរពោរក្រហមអោយយើងស៊ីកាលនឹងដូចជាជ្រូកអីចឹងណាកាលនឹងនោះ
កាលនៅជំនាន់នឹងនោះ។

កៈ
ហើយកាលនឹងម៉ាមានបានធ្លាប់បានល្មើសនឹងបទវិន័យរបស់គេដែលឬទេកាលនឹងដូចជាបានលួចអីគេដើម្បីនឹងលួចគេដែលឬទេកាលនឹង?

ខ៖
អត់ទេកាលនឹងមិនហ៊ាននោះទេកាលនៅក្នុងជំនាន់នឹងនោះព្រោះអីកាលនឹងខ្លាចគេយកទៅវៃចោលកាលនឹងនោះ
តែបើថាយើងនឹងហ៊ាននឹងគេមុខតែយកយើងនឹងទៅសំលាប់ចោលជាមិនខានហើយកាលនឹងណា
ចឹងហើយបានថាកាលនឹងនោះណាចឹងហើយនឹងបានជាខ្ញុំនឹងសុទ្ធចិត្តអត់ឃ្លានថាបើមើលទៅណាក្បលជង្គុងរបស់ខ្ញុំនឹងវាធំជាងក្បាលរបស់ខ្ញុំទៀតឯនោះព្រោះអីកាលនឹងយើងនឹងវាស្គមចឹងណាហើយពេលនឹងវាអត់មានអីសំរាប់ហូបហើយយើងក៏ឃ្លានខ្លាំងណាស់ដែលប៉ុន្តែយើងនឹងមិនមានអីសំរាប់នឹងយកមកហូបយើងនឹងមិនហ៊ានទៅលួចគេយករបស់នេះរបស់នោះទេកាលនឹងនោះយើងនឹងវាមិនហ៊ានទេកូនអើយចឹងហើយសុខចិត្តថាអោយវាអត់ហើយអត់មកដល់សព្វថ្ងៃនឹងមិនអោយគេនឹងថាទេដូចថាបើថាយើងនឹងបានអត់ទៅហើយនឹងកុំអោយគេនឹងបានថាយើងទៀតទៅ កុំអោយគេនឹងបានពិបាកដោយសារយើងនឹងណាកូននឹងយើញចឹងណាកូនខ្ញុំណាចឹងហើយពេលនឹងរហូតមកដល់ឥឡូវនឹងសុខចិត្តអត់នឹងណាកូនអីចឹងមកនឹងដើម្បីនឹងចិញ្ចឹមកូនមកតិកតក់ចឹងទៅ
កាលពីជំនាន់នឹងនោះហើយកាលនឹងប្តីខ្ញុំនឹងបានចប់ពីជំនាន់អាពតមកនឹងបានមកធ្វើជាអ្នករត់កង់បីជាអ្នករត់តុកៗនឹងទេដើម្បីនឹងចិញ្ចឹមប្រពន្ធនឹងចិញ្ចឹមកូន
ហើយខ្ញុំពេលដែលបានចប់ពីអាពតមកហើយនឹងខ្ញុំបានឈឺព្រោះអីកាលនឹងដូចថាពេលដែលយើងបានចប់អាពតមកនឹងខ្ញុំនឹងបានឈឺចឹងទៅហើយក៏ឡើងបាក់ចឹងព្រោះអីកាលនឹងយើងនឹងវាបានធ្វើការពេកកាលជំនាន់នឹងនោះ
មានបានលាក់កំបាំងអីនោះទេកាលនៅជំនាន់នឹងនោះវាដូចថាវាធ្វើការងារខ្លាំងពេកចឹងហើយពេលនឹងមិនហ៊ាននឹងធ្វើការងារអីតិចៗទេព្រោះកាលនឹងពេលយើងឈឺអីនឹងទៅប្រាប់គេទៅគេបានយើងនឹងឈឺពុកឈឺទន្សាយអីចឹងទៅណាចឹងណាកូនអើយចឹងហើយបានជាខ្ញុំនឹងបានបាក់រហូតមកនឹងហើយខ្ញុំវាបានឈឺហើយនឹងវាមិនសូវជាជានឹងដោយសារតែខ្ញុំនឹងបានបាក់ពីជំនាន់អាពតមកនឹងដូចថាពេលនឹងវាធ្វើការងារនឹងវាអស់ពីកំលាំងចិត្តកាយរបស់យើងនឹងណា ពេលនឹងកុំអោយគេនឹងថា
ព្រោះអីកាលនៅសម័យនោះគេមានការប្រជុំហើយទិសទាញគ្នាលើកមកនិយាយនៅពេលប្រជុំនឹងណាចឹងហើយកាលនឹងវាវេទនាណាស់កាលនឹងនោះ។

កៈ
ចឹងកាលនៅសម័យនឹងម៉ាមានបានមើលឃើញមនុស្សគេយកទៅសំលាប់ចោលដែលឬទេកាលនៅក្នុងសម័យនោះនឹង?

ខៈ
ខ្ញុំនឹងវាមិនដែលធ្លាប់បានឃើញនោះទេកូនកាលជំនាន់នោះណាកាលនឹងខ្ញុំនៅធ្វើស្រែនឹងខ្ញុំមិនដែលធ្លាប់បានឃើញទេកាលនឹង
ពេលដែលខ្ញុំបានធ្វើស្រែនៅក្នុងស្រែខាងនែសនឹងខ្ញុំមិនដែលបានឃើញមែនកាលនឹងនោះ
គ្រាន់ថាពេលនឹងគេបានធ្លាប់ប្រើយើងនឹងពេលនឹងគេបានប្រើយើងមែនកាលនៅជំនាន់នឹងនោះ
ប្រើមែនប្រើហើយគេអោយយើងស៊ីវិញនឹងវាមិនសូវបានដេតដល់ទេកាលនឹងនោះវាប្រើយើងខ្លាំង
ហើយបើគ្រង់វាយកមនុស្សទៅសំលាប់ខ្ញុំមិនបាននឹងមើលឃើញមែនកាលនឹងនោះមិនបានមើលឃើញនឹងភ្នែកទទេនោះទេ ។

កៈ ចាស!
ហើយទៅម៉ាពេលដែលម៉ាបានដាច់ពីជំនាន់អាពតនឹងមកតើម៉ាបានគិតថាម៉ាធ្វើយ៉ាងដើម្បីនឹងចិញ្ចឹមជីវិតអីនឹងហើយចឹងតើពេលក្នុងកាលនឹងតើម៉ាមានបាននឹងឃើញទិដ្ឋភាពអីដែលម៉ាចង់ចាំជាងគេពីអាពតមកដល់ឥឡូវនឹង?

ខៈ ពេលដែលបានចប់មកនឹងខ្ញុំបានធ្វើចំការ
២នាក់ប្តីប្រពន្ធនឹងកន្លងមកហើយពេលបានធ្វើចំការហើយនឹងបានខ្ញុំធ្វើត្បាញ
ខ្ញុំបានត្បាញក្រមាអីចឹងណាកូនចាសតែប៉ុណ្ណឹងខ្ញុំបានធ្វើតែប៉ុណ្ណឹង?ចាស!

កៈ ចាស!
ហើយមានរឿងអីគេដែលម៉ាបានចង់ចាំថាពេលដែលម៉ាបាននឹងឃើញហើយនឹងធ្វើអោយម៉ាបានសប្បាយចិត្តជាងគេនៅក្នុងជីវិតរបស់ម៉ា?រឿងដែលធ្វើអោយម៉ាសប្បាយចិត្តនៅក្នុងជីវិតមានដែលឬទេម៉ា?

ខ៖ ហឺ!!
សព្វថ្ងៃនឹងរឿងថាសប្បាយនឹងដូចជាមិនទាន់មានទេសព្វថ្ងៃនឹងហើយនិយាយពីរឿងថានឹកឃើញហើយនឹងសប្បាយនឹងវាមិនទាន់មាននោះទេព្រោះអីពេលដែលបាននឹងឃើញមនឹងមានតែរឿងដែលទុក្ខរហូតនឹងសព្វថ្ងៃនឹង
ដូចថាកូនវាអត់រកមិនបានដល់ចឹងទៅកាលសប្បាយនៅក្នុងខ្លួននឹងដូចថាវាអត់
ចឹងហើយពេលខ្លះនឹងវាបានដែលប៉ុន្តែវាបានតែមួយគ្រាប់គ្រាន់ហើយមួយទៀតនឹងគឺវាខ្វះចឹងហើយបានថា
ដូចជាកូនៗខ្ញុំនឹងសព្វថ្ងៃនឹងគ្មានបានថាដូចជាខ្ញុំឥឡូវនឹងហើយអោយខ្ញុំនឹងថាអោយខ្ញុំនឹងបានសប្បាយចិត្តបានកូនធូធារអីនឹងគឺវាអត់ទាន់នោះទេ
ដូចថាវានៅក្នុងការព្រួយបារម្ភនោះក្នុងខ្លួនចឹងហើយពេលនឹងបានជាវានៅពេលឥឡូវនឹងខ្ញុំបានសប្បាយដោយសារអីហើយកូនគេបានមានគេរកស៊ីបានមានបានអីទៅចឹងយើងបានសប្បាយចិត្តហើយកូនណា

ក៖ ចាស!!!

ខ៖
តែនេះវាកូននៅជីវៈភាពវារាងនៅខ្សត់ខ្សោយវានៅរកមិនបានអានឹងចឹងណាកូនខ្ញុំនឹងវារាល់ថ្ងៃនឹងវានៅមិនទាន់បានដឹងថាអានឹងវានៅកន្លែងណាអោយសប្បាយចិត្តនៅឡើយនោះទេដូចថាឥឡូវនឹងវានៅពិបាកចិត្តទាំងកាយ
តែកាយយើងនឹងវាមិនសូវជាបានលំបាកអីទេព្រោះអីយើងវាមានអាយុនឹងវ័យប៉ុណ្ណឹងហើយចឹងវាមិនទៅអោយលំបាកណាទេព្រោះយើងមានវ័យប៉ុណ្ណឹងហើយនឹង
ចឹងបានតែអង្គុយតែខាលស្វូត្រទេ តែគ្រាន់តែវាពិបាកចិត្តត្រង់កូនយើងនឹងវានៅអត់
ចាសនៅត្រង់នឹងវាមិនទាន់មាននៅចំនុចណាដែលធ្វើអោយខ្ញុំបានសប្បាយចិត្តនៅឡើយនោះទេ។

ក៖ ចាស!
ហើយពេលដែលមានការពិបាកចិត្តម្តងៗតើម៉ាមានជាដំណោះស្រាយយ៉ាងម៉េចដែរសំរាប់ធ្វើអោយបានល្អជាងមុខនឹងដូចជាពេលដែលម៉ាមានទុក្ខលំបាកអីចឹងតើម៉ាធ្វើយ៉ាងណាដូចជាមានការខំប្រឹងធ្វើការឬយ៉ាងណាដែលដើម្បីនឹងបំបាត់ទុក្ខ ?

ខ៖
បើជូនកាលនឹងខ្ញុំនឹងអង្គុយតែខាលសូត្រទៅព្រោះអីកាលនឹងនោះវាមានតែខាលសូត្រនឹងបានវាជួយអោយខ្ញុំបានរំសាយទុក្ខបានខ្លះ
ចឹងវាមានតែប៉ុនឹងមានតែការងារខាលសូត្រនឹងបានជាខ្ញុំនឹងបានជួយការលំបាកខ្ញុំបានខ្លះចឹងបានតែទៅខាលសូត្រអីចឹងទៅណាកូន

ក៖ ចាស!!

ខ៖ ចាស!មានតែប៉ុណ្ណឹង

ក៖
ហើយអើកាលដែលម៉ាមានវ័យកាលនៅពីតូចនឹងម៉ាមានធ្លាប់បានស្រមៃថាម៉ាចង់ធ្វើអ្វីដែលឬទេពេលដែលធំឡើង?

ខ៖
កាលសម័យនឹងចេះតែចង់ធ្វើហើយកាលនឹងតែដូចថាកាលនឹងខ្ញុំនឹងវាមិនមានសម្មតិភាពចឹងណាចឹងហើយយើងទៅចង់អីបើកាលនឹងយើងនឹងវាគ្មានលទ្ធភាពទៅហើយនឹងកាលនឹងគ្មានបាននឹងឃើញចង់ធ្វើអីនោះទេកាលនឹងព្រោះអីបើកាលនឹងម្ដាយឪយើងនឹងវាអត់អត់មានអីសំរាប់ចិញ្ចឹមជីវិតមកនឹងចឹងណាកូនអើយមានតែប៉ុណ្ណឹង។

ក៖ ចាស!!!

ខ៖ ខ្ញុំសព្វថ្ងៃនឹងខ្ញុំមានតែប៉ុណ្ណឹងវាមានតែប៉ុណ្ណឹងណា

ក៖ ចាស!!!

ខ៖ ចាសខ្ញុំមានតែប៉ុណ្ណឹងទេកូន

ក៖
ហើយអើម៉ាកាលពេលមុខនឹងម៉ាមានចូលចិត្តលេងល្បែងប្រជាប្រិយដែលឬទេដូចជាល្បែងបោះអង្គុញ

លាក់កន្សែងយើងណាម៉ាអីនឹងដែលជារបស់ខ្មែរៗយើណាចឹងម៉ាមាននៅចាំដែរឬទេថាមានល្បែងណាមួយដែលម៉ាចូលចិត្តជាងគេហើយចូលចិត្តនៅក្នុងការលេង?

ខ៖ ចាស!!

ក៖ ចាស!ចឹងម៉ាមានបាននៅចាំដែលឬទេ
តើល្បែងណាមួយដែលម៉ាចូលចិត្តជាងគេហើយម៉ាចូលចិត្តលែង?

ខ៖
មានតែល្បែងបោះអង្គុញនឹងមែនមានតែអានឹងទេកាលនឹងកាលដែលពីពេលដែលខ្ញុំនឹងមិនទាន់មានគ្រួសារណា។

ក៖ តើម៉ាបានលេងនៅឯណាដែលម៉ា?

ខ៖ នៅនឹងភូមិយើងនឹងនៅក្នុងភូមិយើងនឹងនាំគ្នាលោតជុំគ្នាចឹងទៅ
នាំគ្នាលេងជុំគ្នាចឹងទៅកាលនឹងនោះនៅក្នុងភូមិនឹងទៅនាំគ្នាលេងបោះអង្គុញនៅក្នុងភូមិយើងនឹងទៅ។

ក៖ ចាស!ហើយសប្បាយ។

ខ៖ ចាស!សប្បាយនៅក្នុងភូមិ។

ក៖ ចាស!ម៉ាហើយម៉ាមានចូលចិត្តស្តាប់បទចម្រៀងដែរឬទេ?

ខ៖ មិនសូវទេខ្ញុំមិនសូវជាចំណូលនោះទេ ហាហា

ក៖ ហាហាចឹងម៉ាមិនសូវជាចូលចិត្តទេ?

ខ៖ ចាស!មិនសូវជាចំណូលទេ។

ក៖
ហើយអើយចឹងកាលដែលនៅពីក្មេងៗនឹងបន្ទាប់ពីម៉ាដូចថាបានឆ្លងកាត់វ័យនឹងហើយដូចថាម៉ាបានមកដល់នៅក្នុងសម័យនឹងម៉ាគិតថាកាលពីសម័យម៉ានៅក្មេងៗនឹងហើយពេលឥឡូវនឹ

ងម៉ាគិតថាបទពិសោធន៍របស់ម៉ាផ្សេងគ្នាយ៉ាងណាដែល ដែលបានធ្វើអោយម៉ាចង់ចាំរវាងពីរនឹង?

ខ៖ ហឺ!កាលនៅពីក្មេងមកដល់ឥឡូវនឹងគ្មានអ្វីចង់ចាំដូចថា បើថាចង់ចាំនឹងគឺចង់ចាំពីរឿងការងារដែលបានធ្វើនឹងតែម្តងហើសចឹង។ ចាសចង់ចាំនឹងតែពីរឿងការធ្វើការហើយត្បាញ់រវៃនឹងតែម្តងនឹងណាកូន គ្មានមុខរបរអីផ្សេងពីនឹងគឺមានតែកាលពីមុនមកនឹងខ្ញុំបានត្បាញក្រមាអីចឹងទៅណាកូន ត្បាញក្រមានឹងសំពត់នឹងបានតាំងពីចាប់ដឹងក្តីខ្ញុំបានឈប់បង្រៀនមកនឹងខ្ញុំបានមកចាប់ធ្វើក្រមាននឹងយើងបានធ្វើក្រមានឹងដើម្បីនឹងចិញ្ចឹមជីវិតមករហូត មកដល់សព្វថ្ងៃនឹងណាកូនហើយមកទល់មកដល់សព្វថ្ងៃនឹងណាកូនហើយមកដល់សព្វថ្ងៃនឹងហើយពេលដែលវាធ្វើមិនកើតនឹងណាបានជាខ្ញុំនឹងទៅធ្វើការចាក់ទៅវិញទៅ ព្រោះអីខ្ញុំវាត្បាញលែងកើតហើយចាសចឹងតែប៉ុណ្ណឹងនោះទេកូនអើយ។

ក៖ ចាស!ចឹងម៉ាជាចុងក្រោយតើម៉ាមានពាក្យពេជ្យអ្វីដើម្បីនឹងផ្តាំផ្ញើរក៏ដូចជាក្មេងពីជំនាន់ក្រោយទៀតក៏ដូចជាអ្នកដែលគេបានស្តាប់សំលេងរបស់ម៉ា?

ខ៖ ចុងក្រោយនឹងខ្ញុំគ្រាន់តែមានមតិនឹងយោលបល់ថាអោយទៅជំនាន់ក្រោយៗទៀតនឹងត្រូវតែចាំថាអោយកូនចៅចាំទៅព្រោះអីកាលដែលខ្ញុំនឹងវាវេទនាចឹងណាពីមុនមកនឹងកាលពីជំនាន់អាពតមកនឹងវាវេទនាណាស់ចឹងហើយអោយក្មេងៗជំនាន់ក្រោយនឹងអោយខំតស៊ូលះបង់កុំអោយប្រើប្រាស់គ្រឿនញៀនចឹងណា កុំចូលចិត្តវាព្រោះអីអាណឹងវាធ្វើអោយសង្គមវាស្អប់ខ្ពើមចឹងណាចឹងហើយកុំអោយធ្វើចឹងអីអោយតែតស៊ូបានជ្រៅជ្រះទៅចាស ម៉ែមានតែពាក្យតែប៉ុណ្ណឹងនោះទេសំរាប់អោយកូនចៅខិតខំតស៊ូអោយបានការងារធ្វើទៅណានឹងវាមិនវេទនា។

ក៖ ចាស!!!

ខ៖
ដូចខ្ញុំចឹងវាវេទនាណាស់ដូចថាយើងនឹងវាមិនបានចេះដឹងបានជ្រៅជ្រះនឹងគេចឹងហើយវាវេទនាណាស់ចឹងហើយកូនចៅជំនាន់ក្រោយនឹងសូមអោយគេដូចជាកូនចៅជំនាន់ក្រោយនឹងដូចថាអោយបានរៀនសូត្រជ្រៅជ្រះចឹងទៅហើយបានធ្វើការងារអីវាបានធូរគិតគូអីក៏វាបានសំរេចកុំអោយដូចជាជំនាន់ខ្ញុំ ព្រោះអីកាលជំនាន់ខ្ញុំនឹងវេទនាទៅហើយគ្រាន់តែចឹងទេណាកូន។

ក៖ ចាស!!
ចាសចឹងអរគុណម៉ាច្រើនដែរថ្ងៃនេះបានផ្តល់ឧកាសសំរាប់ធ្វើការសំភាសន៏ចឹងហើយថ្ងៃនេះខ្ញុំសូមអនុញ្ញាតយកសំលេងរបស់ម៉ាយកទៅដាក់នៅខាងវេបសាយរបស់សាលានៅខាងសហរដ្ឋអាមេរិចចឹងម៉ាអនុញ្ញាតអោយខ្ញុំដើម្បីនឹងដាក់សំលេងមួយនឹងដែលឬទេម៉ា?

ខ៖ ចាស!!បាន

ក៖ ចាស!ចឹងអរគុណច្រើនម៉ាចឹង៕